**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**
**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ
លេខ........................................

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែមីនា ឆ្នាំ២០២៣

**ក-អំពីកម្លាំង៖**

- សរុបរួមចំនួន៖ ០៥រូប (ស្រី០២រូប)

- អវត្តមាន៖ ០២រូប (ស្រី០១រូប) (ចូលរួមវគ្គបណ្ដុះបណ្ដាលនៅបណ្ឌិត្យសភានគរបាលកម្ពុជា)

**ខ-សកម្មភាព និងលទ្ធផលការងារ**

-កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាងគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

***<u>សកម្មភាពក្នុងស្រុក</u>***

- **ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមបើកកិច្ចប្រជុំត្រៀមរៀបចំ កម្មវិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០២២ និងទិសដៅការងារឆ្នាំ ២០២៣ របស់ គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន និងមន្ត្រីពាក់ព័ន្ធ ក្រុមការងាររបាយការណ៍នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងមកពីអង្គការដៃគូរអភិវឌ្ឍនានា មានដូចជាអង្គការ CWCC, IJM , ADRA , IOM, ការីតាសស្វីស, ចាប់ដៃ, Asian Act, UNICEF, Nomi Network, Caritas Cambodia, មូលនិធីហាហ្គា, AIM, Winrock, WHI, Erik, ដៃនដីមនុស្សហូឡង់ និងអង្គការផ្នែកច្បាប់ការពារសិទ្ធស្ត្រី និងកុមារ។

- **ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំផ្ទៀងផ្ទាត់របាយការណ៍ឆ្នាំ២០២២ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ អញ្ជើញចូលរួមមាន លោកជំទាវឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់

អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង លោកប្រធានក្រុមជំនួយកិច្ចការទាំង៦ អនុប្រធានលេខាធិការដ្ឋាន ទទួលបន្ទុករបាយការណ៍ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

- **ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមជួបប្រជុំសំណេះសំណាល ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីជានារីចំណុះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្នុងឱកាសអបអរសាទរទិវាសិទ្ធិនារីអន្តរជាតិ ៨មីនា ឆ្នាំ២០២៣ ខួបលើកទី១១២ ក្រោមប្រធានបទ «ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍសង្គម ក្នុងយុគសម័យឌីជីថល» ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ កិច្ចប្រជុំនោះផងដែរមានការអញ្ជើញចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានក្រុមជំនួយកិច្ចការទាំង៦ ប្រធានលេខាធិការដ្ឋាន នាយ/នាយរងការិយាល័យ និងមន្ត្រីនគរបាលជាស្ត្រីទាំងអស់ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

- **ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២** ឯកឧត្តម ឧត្តមសេនីយ៍ត្រី តែ សុថារេត អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការអនុវត្តច្បាប់ ដោយមានការចាត់តាំងពីលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមតំណាងក្នុងនាមលោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរងក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ អន្តរជាតិ ក្នុងកិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារខមមីតកម្ពុជា ក្រោមអធិបតីភាព **លោកជំទាវ ហ៊ូ សាមិត្ត** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារ សហប្រតិបត្តិការអន្តរជាតិ (គ.ជ.ប.ជ) និងប្រធានក្រុមការងារ មហាអនុតំបន់មេគង្គខមមីតកម្ពុជា។ គោលបំណងនៃកិច្ចប្រជុំ គឺដើម្បីផ្សព្វផ្សាយលទ្ធផល នៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីខមមីតជាពិសេសពិភាក្សា ពីតួនាទី ភារកិច្ច និងទិសដៅបន្តរបស់កម្ពុជា ក្នុងការធ្វើជាប្រធានប្តូរវេនខមមីត និងពិភាក្សាពីស្ថានភាពបច្ចុប្បន្ន នៃអំពើជួញដូរមនុស្សនៅកម្ពុជា រៀបចំយន្តការបញ្ជូនឆ្លងដែន និងយន្តការបញ្ជូនថ្នាក់ជាតិ ចែករំលែកបទពិសោធន៍ល្អៗ បញ្ហាប្រឈម និងទិសដៅបន្តរបស់ក្រុមការងារ។ លោកឧត្តមសេនីយ៍ត្រី តែ សុថារេត បានអញ្ជើញធ្វើបទបង្ហាញសង្ខេបស្តីពីស្ថានភាពបច្ចុប្បន្ននៃ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា និងបានឆ្លើយសំនួរពិភាក្សា នៅក្នុងកិច្ចប្រជុំផងដែរ។ សមាសភាពអញ្ជើញចូលរួមក្នុង កិច្ចប្រជុំមានលោកឧត្តមសេនីយ៍ត្រី តាវ វិភក្តិ ប្រធានក្រុមជំនួយកិច្ចការស្តីទីក្រុមការងារសហប្រតិបត្តិការជាតិ អន្តរជាតិ លោកវរសេនីយ៍ត្រី ឆន ដារ៉ារិទ្ធ នាយរងការិយាល័យ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងមកពីក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស តំណាងនាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម តំណាងក្រសួងយុត្តិធម៌ តំណាង UNDP តំណាងអង្គការ IOM អង្គការសម្ព័ន្ធចាប់ដៃ និងដៃគូពាក់ព័ន្ធសរុបចំនួន ៤៣រូប (ស្ត្រី១៩រូប)។

- **ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣** ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ បានចូលរួមក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ជាតិឆ្នាំ ២០២២ និងលើកទិសដៅការងារឆ្នាំ ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ។ មានវត្តមាន អញ្ជើញចូលរួមក្នុងអង្គពិធីមាន ថ្នាក់ដឹកនាំក្រសួង-ស្ថាប័នជាប្រធាននិង អនុប្រធាន សមាជិក នៃក្រុមការងារអន្តរក្រសួងទាំង៦ នៃ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិការ នៃ គ.ជ.ប.ជ និងរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មាន លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ លោកជំទាវ អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន ប្រធាននៃក្រុមជំនួយកិច្ចការទាំង៦ មន្ត្រីបច្ចេកទេស មន្ត្រីរបាយការណ៍ មន្ត្រីក្រោមឱវាទ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ឯកឧត្តម លោកជំទាវ អភិបាល អភិបាលរងជាប្រធាន គ.ខ.ប.ជ និងប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ នៃគណៈអភិបាលរាជធានី-ខេត្តទាំង ២៥ លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត កុងស៊ុល និងតំណាងបេសកកម្មនៃបណ្តាប្រទេសជាមិត្តប្រចាំនៅកម្ពុជា ជាប្រធាន ឬតំណាងអង្គការ សហប្រជាជាតិ អង្គការ អន្តរជាតិ អង្គការសង្គមស៊ីវិល ដែលកំពុងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធជាច្រើនរូប សរុបប្រមាណ ៣០០នាក់ ។

- **ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣** លោកឧត្តមសេនីយ៍ត្រី តាវ វិភក្តិ អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាដើម្បីផ្តល់ធាតុចូលស្តីពីការពង្រឹងការការពារ និងផ្តល់សេវាដល់ជនរងគ្រោះនៅកម្ពុជា សម្រាប់ជាមូលដ្ឋានក្នុងការផ្តល់ការគាំទ្រ ការអនុវត្ត គម្រោង ក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ។ អញ្ជើញចូលរួមពី ឯកឧត្តម ឧត្តមសេនីយ៍ឯក លី តុងហ៊ុយ អគ្គលេខាធិការរង គ.ជ.ប.ជ ឯកឧត្តម ឧត្តមសេនីយ៍ទោ នី គឹមស្រេន អគ្គលេខាធិការរង គ.ជ.ប.ជ ឯកឧត្តម ឧត្តមសេនីយ៍ត្រី តែ សុថារេត អគ្គលេខាធិការរង គ.ជ.ប.ជ លោកវរសេនីយ៍ឯក ជា ឆៃរី អនុប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ។

- **ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣** លោកជំទាវ ឧត្តមសេនីយ៍ទោ វ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេសថ្នាក់ជាតិ ស្តីពីការពិនិត្យកែសម្រួលផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសណ្ឋាគារ SUN & MOON រាជធានីភ្នំពេញ។ កិច្ចប្រជុំនេះមានការសហការពីអង្គការ IOM ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម ញ៉ឹក វណ្ណារ៉ា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ឯកឧត្តម សៀក សុជាតិ រដ្ឋលេខាធិការក្រសួងការពារជាតិ លោកជំទាវ សួស រដ្ឋាវី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តម សាម៉ន បណ្ឌិត រដ្ឋលេខាធិការក្រសួងព័ត៌មាន លោកជំទាវ ឡុង សុផល្លី អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី លោកជំទាវ ជូ ពុទ្ធានី អនុរដ្ឋលេខាធិការក្រសួងផែនការ ឯកឧត្តម ម៉ៅ តាន់អ៊ាង អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័នអង្គការដៃគូពាក់ព័ន្ធ និងមន្ត្រីបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ៤៧ រូប ស្រី ១១ រូប។

- **ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរងក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួម សិក្ខាសាលាស្តីពី ការផ្សព្វផ្សាយលើការវិភាគស្ថានភាពកុមារ និងក្មេងជំទង់នៅកម្ពុជា ដែលបានរៀបចំដោយអង្គការ យូនីសេហ្វ នៅសណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ ខ្លឹមសារនៃសិក្ខាសាលា បានផ្តោតសំខាន់លើ ការរកឃើញសំខាន់ៗនៃស្ថានភាពកុមារ និងមនុស្សវ័យជំទង់នៅក្នុងប្រទេស និងការអន្តរាគមន៍ដ៏មានសក្តានុពល នៃកម្មវិធីថ្មីរបស់យូនីសេហ្វ សម្រាប់ឆ្នាំ ២០២៤ - ២០២៨។ អញ្ជើញចូលរួមក្នុង សិក្ខាសាលានេះមានតំណាង ក្រសួង ស្ថាប័ន និងអង្គការដៃគូរពាក់ព័ន្ធ សរុបចំនួនប្រមាណ ៧០នាក់ ព្រមទាំងមានការចូលរួម តាមរយៈអនឡាញ មួយចំនួនទៀត។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២៣

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ**